**គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា**
**ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ**
**The Cambodian NGO Committee on CEDAW (NGO-CEDAW)**
**#16 , Street 99, Boeung Trabek, Chamcamorn, Phnom Penh**
**Website: www.ngocedaw.org-, E-mail: ngocedaw. pnh@gmail.com**

# សេចក្តីថ្លែងការណ៍

ADHOC
AMARA
AR
BSO
BWAP
CCFC
CADEA
CADPP
CAMBOW
CCIM/VOD
CCPCR
CD Cam
CDP
CDWN
CDPO
CFSWF
CHEC
CLEC
CLC
CICA
CMH
CODO
COSECAM
CPWP
CSD
CYN
CUMA
CWCC
CWDA
CWMO
CWPD
DAC
EDCO
FAA
GAD/C
GGAC
IDA
IDEA
HIPPO
KFDA
KHEMARA
KWCD
KWVC
KYA
LAC
LICADHO
LSCW
ML&NV

យើងខ្ញុំទាំងអស់គ្នាជាសមាជិកនៃ**គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW) ដែលជាសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលធ្វើការដើម្បីភាពរីកចំរើននៃសិទ្ធិរបស់ស្ត្រី** មានការតក់ស្លុតយ៉ាងខ្លាំង ចំពោះការបង្ក្រាបដោយហិង្សា និងការប្រើអំពើហិង្សាហួសហេតុ ទៅលើក្រុមកម្មករ និងក្រុមបាតុករ ពីសំណាក់កងកម្លាំងសន្តិសុខ ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ នៅមុខរោងចក្រ**យ៉ាកជីន** នៅតាមដងផ្លូវ**វេងស្រេង និងនៅទីលានប្រជាធិបតេយ្យ**។

ការបង្ក្រាបយ៉ាងឃោឃៅទាំងនេះដោយកងកម្លាំងប្រដាប់អាវុធចម្រុះ ទៅលើក្រុមបាតុករដែលក្នុងនោះរួមមានស្ត្រី និងកុមារផងដែរ បានបង្កឲ្យមានមនុស្សស្លាប់យ៉ាងតិចបួននាក់ដោយសារគ្រាប់កាំភ្លើង និងរងរបួសចំនួន ៤០នាក់ ដែលអ្នករងរបួសភាគច្រើនបណ្តាលមកពីគ្រាប់កាំភ្លើង។

បន្ទាប់ពីការបង្ក្រាបដោយហិង្សាពីសំណាក់កងកម្លាំងប្រដាប់អាវុធចម្រុះ (មានកងរាជអាវុធហត្ថ យោធា និងនគបាល) ទៅលើក្រុមកម្មករដែលកំពុងធ្វើការតវ៉ាដើម្បីការពារសិទ្ធិរបស់អ្នកទាំងនោះ បាតុករ និងអ្នកការពារសិទ្ធិមនុស្សចំនួន ២៣នាក់ ត្រូវបានចាប់ខ្លួន។

ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួន ក្នុងនោះ មានលោក **វន់ ពៅ** ជាប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ )IDEA) និងលោក **ថេង សាវឿន** អ្នកសម្របសម្រួលនៃសម្ព័ន្ធសហគមន៍កសិករកម្ពុជា )CCFC)។ អ្នកទាំងពីរជាសមាជិករបស់ NGO-CEDAW។

បាតុករ ២៣នាក់ទាំងនេះ ត្រូវបានឃុំខ្លួន និងបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី៣ និងទី៤ ខែមករា ឆ្នាំ២០១៤។ ពួកគាត់ទាំង ២៣នាក់ ត្រូវបានជាប់ចោទពីបទល្មើសចំនួនពីរ គឺ ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស និងធ្វើអោយខូចខាតដោយចេតនាដោយមានស្ថានទម្ងន់ទោស ដែលបទល្មើសនីមួយៗត្រូវជាប់ពន្ធនាគារចាប់ពី ២ ឆ្នាំ រហូតដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ចំនួនពី ១,០០០ ដុល្លារ ទៅ ២,៥០០ ដុល្លារអាមេរិក។ បច្ចុប្បន្នអ្នកទាំងអស់នេះ ត្រូវបានតុលាការសម្រេច ឃុំខ្លួនបណ្តោះអាសន្នដើម្បីស៊ើបអង្កេត និងរង់ចាំសវនាការ។ យើងក៏មានការព្រួយបារម្ភផងដែរពីទីកន្លែងឃុំឃាំងរបស់អ្នកទាំងនេះ ដែលត្រូវបានអាជ្ញាធររក្សាជាអាថ៌កំបាំង អស់រយៈពេលប្រាំពីរថ្ងៃ។

យើងខ្ញុំទាំងអស់ សូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាល សូមមេត្តាដោះស្រាយបញ្ហាដោយសន្តិវិធី សូមកុំប្រើអំពើហិង្សា និងសូមមេត្តាធ្វើការដោះលែងបាតុករទាំងអស់ជាបន្ទាន់ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការចាប់ខ្លួន។

NAPA
NEP
NGO Forum
NICFEC
OI
PCC
RHB
SILAKA
SK
SSC
VAWCC
VYCD
WDA
WFP
WHIAD
WMC
WOSO
YRDP

យើងក៏សូមទាមទារឲ្យបើកការស៊ើបអង្កេតជាសាធារណៈដើម្បីស្វែងរក និងធ្វើការកាត់ទោសដល់អ្នកប្រព្រឹត្តបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរទាំងនេះ ដូចជា ការបញ្ជាឲ្យបាញ់គ្រាប់ពិតលើប្រជាជនស្លូតត្រង់ដែលបណ្ដាលឲ្យមានអ្នកស្លាប់ និងរបួសជាច្រើននាក់។

ធ្វើនៅភ្នំពេញ ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៤

**សម្រាប់ពត៌មានបន្ថែម សូមទំនាក់ទំនង:**


-កញ្ញា **អ៊ូ ទេពផល្លីន** លេខទូរស័ព្ទ: ០១១ ៩៨៩ ៨៨៣/០៩៨ ៩៨៩ ៨៨៣

Email: phallin@cfswf.org

-លោក **ហេង សំអ៊ិន** លេខទូរស័ព្ទ: ០១៥ ៧៧០ ១២០

Email: orn_idea@yahoo.com